ANGKOR RESEARCH
LOCAL KNOWLEDGE. INTERNATIONAL STANDARDS

វេទិកាអនាគត FUTURE FORUM

# ផលប៉ះពាល់នៃកូវីដ-១៩ ទៅលើកសិករ

## អនុក្រមនៃលទ្ធផលសង្ខេប[1] ទិន្នន័យជុំទី១ ខែតុលា ឆ្នាំ២០២០

## ដោយ ក្រុមហ៊ុនអង្គរស្រាវជ្រាវ និង វេទិកាអនាគត[2]

ក្នុងឆ្នាំ ២០២០ វិស័យកសិកម្មនៅតែដើរតួនាទីសំខាន់ក្នុងសេដ្ឋកិច្ចកម្ពុជា ដោយបានចូលរួមប្រមាណ ២២% នៅក្នុង GDP[3] និងបានផ្តល់ការងារប្រមាណមួយភាគបីនៃកំលាំងពលកម្មក្នុងប្រទេស។ ប៉ុន្តែគួរអោយកត់សំគាល់ផងដែរថា ចាប់តាំងពីមុនពេលនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ដែលធ្វើអោយប៉ះពាល់ជាសាកល ការរីកចម្រើននៃវិស័យកសិកម្ម[4] បានកំពុងធ្លាក់ចុះទៅហើយជាមួយនឹងការថយចុះក្នុងឆ្នាំ ២០១៩ ដោយវាជាការធ្លាក់ចុះដំបូងក្នុងរយៈពេលដប់ប្រាំឆ្នាំចុងក្រោយ។ ការធ្លាក់ចុះនេះ មួយផ្នែកធំបណ្តាលមកពីការរាំងស្ងួតរយៈពេលយូរដែលកើតឡើងចាប់តាំងពីឆ្នាំ២០១៣ ធ្វើអោយកសិករកម្ពុជាជាច្រើនបានធ្វើចំណាកស្រុកទៅក្រៅប្រទេស ដើម្បីធានាបានសុវត្ថិភាពប្រាក់ចំណូលទប់ទល់នឹងភាពមិនទៀងទាត់នៃទិន្នផលដែលគេទទួលបាន[5]។ ថ្វីបើមានកង្វល់អំពីសេដ្ឋកិច្ច និងសុខាភិបាលក្នុងកំឡុងពេលការរាលដាលនៃជំងឺកូវីដ-១៩ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា បានចាត់ទុកវិស័យកសិកម្មជាប្រភពចម្បងនៃការលើកម្ពស់សេដ្ឋកិច្ចជាតិអោយរឹងមាំឡើងវិញក្នុងកំឡុងពេលការឆ្លងរាលនៃជំងឺ[6]។ បើសំដៅលើផលិតផល ស្រូវគឺជាដំណាំដ៏សំខាន់ដែលបានរួមចំណែកប្រមាណពាក់កណ្តាលក្នុងវិស័យកសិកម្ម[7]។ ដោយកសិកម្មបានចូលរួមយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចជាតិ ផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើផលិផលកសិកម្ម ខ្សែចង្វាក់ផលិតកម្ម និងសុវត្ថិភាពស្បៀង គឺមានសារៈសំខាន់ណាស់ដើម្បីតាមដាននិងស្វែងរកដំណោះស្រាយ។

ដោយកត់សំគាល់ពីកង្វះខាតពត៌មាននៅថ្នាក់ក្រោម ដើម្បីផ្តល់ជាជំនួយដល់ការធ្វើគោលនយោបាយឆ្លើយតបនឹងការឆ្លងរាលដាលនៃជំងឺនេះ ក្រុមហ៊ុនអង្គរស្រាវជ្រាវនិងផ្តល់ប្រឹក្សា សហការណ៍ជាមួយវេទិការអនាគត បានផ្តួចផ្តើមការសិក្សាពីផលប៉ះពាល់សេដ្ឋកិច្ចបណ្តាលមកពីកូវីដ-១៩[8] និងការពិក្សាគោលនយោបាយលើការឆ្លងរាលដាលនៃជំងឺនេះ។ គោលបំណងនៃការសិក្សាគឺការជ្រើសយកសំណាកគ្រួសារក្នុងប្រទេសដោយចៃដន្យដើម្បីកំណត់និងវាយតម្លៃផលប៉ះពាល់សេដ្ឋកិច្ចបណ្តាលមកពីកូវីដ-១៩។ **អនុក្រមនៃលទ្ធផលសង្ខេបនេះនឹងផ្តល់ឱកាសដល់អ្នកពាក់ព័ន្ធក្នុងការធ្វើគោលនយោបាយ ដើម្បីស្វែងយល់ពីលទ្ធផលនៃការស្រាវជ្រាវដែលទទួលបានពីការប្រមូលពត៌មាននៃជុំនិមួយៗរបស់គម្រោងស្រាវជ្រាវនេះ។** ផ្នែកបន្ទាប់នៃរបាយការណ៍សង្ខេបនេះនឹងបង្ហាញពីលទ្ធផលនៃផលប៉ះពាល់លើកសិករ។

---

[1] ការសិក្សានេះត្រូវបាន ផ្តួចផ្តើម តាក់តែង និងអនុវត្តដោយក្រុមហ៊ុនអអង្គរស្រាវជ្រាវ និងផ្តល់ប្រឹក្សា ការវិភាគនិងការសរសេររបាយការណ៍គឺធ្វើឡើងក្នុងកិច្ចជាដៃគូរគម្រោងជាមួយវេទិការអនាគត។

[2] ការសិក្សានេះគាំទ្រដោយ រដ្ឋាភិបាលអូស្រ្តាលីតាមរយៈនាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងពាណិជ្ជកម្ម ជាមួយនឹង The Asia Foundation។ ការបង្ហាញក្នុងការសិក្សានេះគឺជាមតិយោលបល់ផ្ទាល់របស់អ្នកនិពន្ធ ដែលមិនជាប់ពាក់ព័ន្ធជាមួយនឹង រដ្ឋាភិបាលអូស្រ្តាលី និង The Asia Foundation ឡើយ។

[3] World Bank (2019)

[4] សំដៅលើការចូលរួមរបស់វិស័យកសិកម្មក្នុង GDP កម្ពុជា.

[5] World Bank (2020)

[6] ត្រូវបានបកប្រែ និងចុះផ្សាយក្នុង VOD.

[7] World Bank (2019)

[8] ប្រើប្រាស់វិធីសាស្រ្តជ្រើសសំណាកតាមក្រុម។ សំណាកបែងចែកជាក្រុមតាមកំរិតខេត្ត ស្រុក និងភូមិ។ ការអង្កេតនឹងត្រូវធ្វើឡើងជាបន្តបន្ទាប់ (longitudinal study) ដែលផ្តោតទៅលើនិយោជិក គ្រួសារដែលមានជំនួយខ្នាតតូច និងកសិករ ក្នុងខេត្តកំពត កំពង់ស្ពឺ ស្វាយរៀង សៀមរាប និងរាជធានីភ្នំពេញ។ សំរាប់ពត៌មានបន្ថែមអំពីការជ្រើសរើសសំណាក និងវិធីសាស្រ្តជ្រើសរើសសូមទាក់ទងមកលោក Ian Ramage តាមរយៈ ian@angkorresearch.com។

## ១. ប្រភេទការងារកសិកម្ម

តារាងទី១ បង្ហាញពីសកម្មភាពកសិកម្មរបស់សំណាកស្រាវជ្រាវ ដោយបានចាត់ថ្នាក់ទៅតាមប្រភេទ និងខេត្តនិមួយៗ។ ជារួម ផលិតកម្មបួនប្រភេទដែលភាគច្រើនមាននៅក្នុងសកម្មភាពកសិកម្មមានដូចជា ស្រូវ ដំឡូងមី ការចិញ្ចឹមសត្វ និងផលិកម្មដំណាំបន្លែ ហើយលទ្ធផលនេះដូចនឹងការរំពឹងទុកជាមួយនឹងទិន្នន័យថ្នាក់ជាតិផងដែរ។ ដោយបែងចែកទៅតាមទីតាំងសិក្សា គ្រប់ខេត្តទាំងអស់ លើកលែងរាជធានីភ្នំពេញ[9] ការដាំដុះដំណាំស្រូវបានឈរនៅលេខរៀងទី១ ឬទី២ជានិច្ច។ ដំណាំដំឡូងមីមានច្រើននៅខេត្តសៀមរាប ការចិញ្ចឹមសត្វមាននៅខេត្តកំពតនិងកំពុងស្ពឺ និងដំណាំបន្លែនៅខេត្តស្វាយរៀង។

**តារាងទី១៖ ដំណាំ ឬសកម្មភាពកសិកម្មរបស់គ្រួសារចាប់តាំងពីខែមករា ឆ្នាំ២០២០[10]**

| ប្រភេទផលិតកម្ម | ភ្នំពេញ | | សៀមរាប | | កំពត | | ស្វាយរៀង | | កំពង់ស្ពឺ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | # | % | # | % | # | % | # | % | # | % | # | % |
| ស្រូវ | 0 | 0 | 44 | 15.4 | 22 | 7.7 | 26 | 9.1 | 6 | 2.1 | **98** | **34.4** |
| ដំឡូងមី | 0 | 0 | 61 | 21.4 | 0 | 0 | 1 | 0.4 | 0 | 0 | **62** | **21.8** |
| ការចិញ្ចឹមសត្វ | 2 | 0.7 | 5 | 1.8 | 32 | 11.2 | 11 | 3.9 | 9 | 3.2 | **59** | **20.7** |
| បន្លែ | 1 | 0.4 | 19 | 6.7 | 5 | 1.8 | 8 | 2.8 | 6 | 2.1 | **39** | **13.7** |
| នេសាទ/ការចិញ្ចឹមត្រី | 1 | 0.4 | 1 | 0.4 | 2 | 0.7 | 1 | 0.4 | 5 | 1.8 | **10** | **3.5** |
| ឈើហូបផ្លែ | 0 | 0 | 2 | 0.7 | 0 | 0 | 4 | 1.4 | 1 | 0.4 | **7** | **2.5** |
| កាប់អុស/រកឈើ | 0 | 0 | 0 | 0 | 5 | 1.8 | 0 | 0 | 0 | 0 | **5** | **1.8** |
| ផ្សេងៗ | 0 | 0 | 0 | 0 | 4 | 1.4 | 0 | 0 | 1 | 0.4 | **5** | **1.8** |
| សរុប | 4 | 1.4 | 132 | 46.3 | 70 | 24.6 | 51 | 17.9 | 28 | 9.8 | **285** | **100** |

## ២. គោលបំណងនៃសកម្មភាពកសិកម្ម

តារាងទី២ បង្ហាញពីទិន្នន័យនៃការប្រែប្រួលគោលគំនិតអាជីវកម្មនៃផលិតផលកសិកម្មរបស់គ្រួសារកសិករ មានដូចជា ផលិតសំរាប់ហូបសំរាប់លក់ ឬរួមបញ្ចូលទាំងហូបនិងលក់។ យើងសង្កេតឃើញថា ការប្រែប្រួលមានតិចតួចចន្លោះខែមករា និងមេសា ប៉ុន្តែតួលេខនេះបានបង្ហាញពីនិន្នាការផ្លាស់ប្តូរពីការផលិតសំរាប់លក់ ទៅរកការផលិតសំរាប់តែហូប ដោយលទ្ធផលបានបង្ហាញថា គ្រួសារចំនួន ៦ បានផ្លាស់ប្តូរទៅការផលិតសំរាប់តែហូប ចំពោះដំណាំស្រូវនិងបន្លែ។

**តារាងទី២៖ ស្ថានភាពនៃសកម្មភាពកសិកម្ម (បែងចែកទៅតាមផលិកម្ម)**

| ប្រភេទផលិតកម្ម | ស្ថានភាព | ខែមករា (Fr.) | ខែមេសា (Fr.) | ភាពខុសគ្នា (Fr.) |
|---|---|---|---|---|
| ស្រូវ (N=98) | សំរាប់តែហូប | 54 | 58 | **4** |
| | សំរាប់តែលក់ | 0 | 0 | **0** |
| | ទាំងពីរ | 44 | 40 | **-4** |
| ដំឡូងមី (N=62) | សំរាប់តែហូប | 0 | 0 | **0** |
| | សំរាប់តែលក់ | 62 | 62 | **0** |

[9] កសិកម្មមិនមែនជាសកម្មភាពសេដ្ឋកិច្ចសំខាន់នៅភ្នំពេញ ដោយចូលរួមតែ ១,៤% ប៉ុណ្ណោះក្នុងកសិកម្មសរុប

[10] បញ្ជាក់៖ Fr. គឺជារបាយចំនួន; N (ចំនួនសំណាក) នៃដំណាំ/សកម្មភាពកសិកម្ម ច្រើនជាង N នៃគ្រួសារដោយសារប្រើទម្រង់សំណួរពហុជ្រើសរើស។

| | | | | |
|---|---|---|---|---|
| | ទាំងពីរ | 0 | 0 | 0 |
| ការចិញ្ចឹមសត្វ (N=59) | សំរាប់តែហូប | 2 | 2 | 0 |
| | សំរាប់តែលក់ | 38 | 38 | 0 |
| | ទាំងពីរ | 19 | 19 | 0 |
| ដំណាំបន្លែ (N=39) | សំរាប់តែហូប | 4 | 6 | 2 |
| | សំរាប់តែលក់ | 9 | 9 | 0 |
| | ទាំងពីរ | 26 | 24 | -2 |
| នេសាទ/ចិញ្ចឹមត្រី (N=10) | សំរាប់តែហូប | 1 | 0 | -1 |
| | សំរាប់តែលក់ | 1 | 1 | 0 |
| | ទាំងពីរ | 8 | 9 | 1 |
| ឈើហូបផ្លែ (N=7) | សំរាប់តែហូប | 1 | 1 | 0 |
| | សំរាប់តែលក់ | 4 | 4 | 0 |
| | ទាំងពីរ | 2 | 2 | 0 |
| កាប់អុស/រកឈើ (N=5) | សំរាប់តែហូប | 0 | 1 | 1 |
| | សំរាប់តែលក់ | 3 | 2 | -1 |
| | ទាំងពីរ | 2 | 2 | 0 |
| ផ្សេងៗ (N=5) | សំរាប់តែហូប | 0 | 0 | 0 |
| | សំរាប់តែលក់ | 2 | 2 | 0 |
| | ទាំងពីរ | 3 | 3 | 0 |
| សរុប (N=285) | សំរាប់តែហូប | 62 | 68 | 6 |
| | សំរាប់តែលក់ | 119 | 118 | -1 |
| | ទាំងពីរ | 104 | 99 | -5 |

### ៣. ការប្រែប្រួលចំណាយផលិតកម្ម បែងចែកទៅតាមប្រភេទផលិតកម្ម និងទីតាំង

ក្រាហ្វិកទី១ បង្ហាញលំអិតអំពីការប្រែប្រួលចំណាយផលិតកម្មចន្លោះខែមករា និងខែមេសា បែងចែកទៅតាមប្រភេទផលិតកម្ម។ លទ្ធផលបង្ហាញថាចំណាយផលិតកម្មមានការធ្លាក់ចុះក្នុងចន្លោះខែទាំងពីរ លើកលែង "ផ្សេងៗ"។ នៅពេលចំណាយផលិតកម្មបែងចែកទៅតាមខេត្តនិមួយៗ យើងឃើញថា និន្នាការធ្លាក់ចុះនេះមាននៅខេត្តកំពុងស្ពឺ កំពត និងសៀមរាបផងដែរ (ធ្លាក់ចុះ ៧៩% ៥៦% និង៧% ទៅតាមលំដាប់ខេត្តរៀបរាប់ខាងដើម)។ ផ្ទុយទៅវិញ ចំណាយផលិតកម្មនៅខេត្តស្វាយរៀង និងរាជធានីភ្នំពេញបានកើនឡើង ៤៥% និង១%។

**ក្រាហ្វិកទី១៖ ចំណាយផលិតកម្មកសិកម្មតាមប្រភេទផលិតកម្ម (គិតជាដុល្លា) ក្នុងចន្លោះខែមករានិងមេសា ឆ្នាំ២០២០**



## ៤. ការប្រែប្រួលចំណូលផលិតកម្ម បែងចែកទៅតាមប្រភេទផលិតកម្ម និងទីតាំង

ក្រាហ្វិកទី២ បង្ហាញពីការប្រែប្រួលចំណូលកសិកម្មតាមប្រភេទផលិកម្ម។ ប្រភេទផលិកម្មនិមួយៗមានការធ្លាក់ចុះគួរអោយកត់សំគាល់ក្នុងចន្លោះខែមករា និងមេសា[11] លើកលែងដំណាំស្រូវ (កើនឡើង ៥១%) ការចិញ្ចឹមសត្វ (មិនប្រែប្រួល)។ នៅពេលបែងចែកទៅតាមខេត្ត លទ្ធផលបង្ហាញថា ចំណូលជាមធ្យមបានធ្លាក់ចុះនៅខេត្តកំពង់ស្ពឺ (៤៦%) កំពត (២៩%) និង សៀមរាប (៤៦%)។ ដោយឡែកចំណូលកសិកម្មក្នុងរាជធានីភ្នំពេញ និងខេត្តស្វាយរៀងមានការកើនឡើង ០,២% និង ២១% រៀងៗខ្លួន។

**ក្រាហ្វិកទី២៖ ចំណូលផលិតកម្មកសិកម្មតាមប្រភេទផលិតកម្ម (គិតជាដុល្លា) ក្នុងចន្លោះខែមករានិងមេសា ឆ្នាំ២០២០**




## ៥. ការប្រែប្រួលចំណេញផលិតកម្ម បែងចែកទៅតាមប្រភេទផលិតកម្ម និងទីតាំង

ក្រាហ្វិកទី៣ បង្ហាញពីទិន្នន័យនៃការចំណេញក្នុងផលិតកម្មកសិកម្មចន្លោះខែមករា និងខែមេសា។ ការចំណេញជាមធ្យមក្នុងប្រភេទផលិតកម្មនិមួយៗ បានធ្លាក់ចុះស្ទើរគ្រប់ប្រភេទនៃផលិតកម្ម[12]។ ដោយលើកលែងដំណាំស្រូវ និងការចិញ្ចឹមសត្វ ដែលការចំណេញផលិកម្មបានកើនឡើងប្រមាណ ៩៨% និង ២១% រៀងខ្លួនទៅតាមលំដាប់។ ខេត្តភាគច្រើនទទួលរងការបាត់បង់ផលចំណេញក្នុងផលិតកម្មកសិកម្ម ដោយខេត្តកំពង់ស្ពឺ កំពត រាជធានីភ្នំពេញ និងស្វាយរៀង ការចំណេញផលិតកម្មជាមធ្យមធ្លាក់ចុះ ២៥% ៣៣% និង ៦% តាមលំដាប់ខេត្តរៀបរាប់ខាងដើម ហើយខេត្តសៀមរាប បានទទួលរងការធ្លាក់ចុះផលចំណេញច្រើនជាងគេគឺប្រមាណ ៥៣%។ ការធ្លាក់ចុះខ្លាំងនៅខេត្តសៀមរាបគឺបណ្តាលមកពីមានការដាំដុះដំណាំដំឡូងមីច្រើនក្នុងខេត្តមួយនេះ។ បើពិនិត្យតែលើដំណាំដំឡូងមីក្នុងខេត្តសៀមរាប ផលចំណេញជាមធ្យមធ្លាក់ចុះពី ១១៦,៤ ដុល្លា ក្នុងខែមករា មកត្រឹមតែ ៣៧,៧ ដុល្លា ក្នុងខែមេសា (ធ្លាក់ចុះ ៦៧,៦%)។

[11] ដំឡូងមីធ្លាក់ចុះ ៦៦%; កាប់អុស/រកឈើធ្លាក់ចុះ ៧០%; នេសាទ/ចិញ្ចឹមត្រីធ្លាក់ចុះ ៤៦%; ឈើហូបផ្លែធ្លាក់ចុះ ៩៥% និងបន្លែធ្លាក់ចុះ ៣២%។

[12] ដំឡូងមីធ្លាក់ចុះ ៨០%; កាប់អុស/រកឈើធ្លាក់ចុះ ៦៥%; នេសាទ/ចិញ្ចឹមត្រីធ្លាក់ចុះ ៥០%; ឈើហូបផ្លែធ្លាក់ចុះ ១៧% និងបន្លែធ្លាក់ចុះ ៣៧%។

ក្រាហ្វិកទី៣៖ ចំណេញផលិតកម្មកសិកម្មតាមប្រភេទផលិតកម្ម (គិតជាដុល្លា) ក្នុងចន្លោះខែមករានិងមេសា ឆ្នាំ២០២០




## ៦. សង្ខេបនៃលទ្ធផល

ជារួមចំណូលពីកសិកម្មបានធ្លាក់ចុះ ៣០% ពី ២៨៣ ដុល្លា ក្នុងខែមករា មក ១៩៥ ដុល្លា ក្នុងខែមេសា។ ការធ្លាក់ចុះនេះកើតឡើងស្ទើរគ្រប់ប្រភេទផលិតកម្ម និងគ្រប់តំបន់សិក្សា។ លទ្ធផលនៃទិន្នន័យជុំទីមួយនេះក៏បង្ហាញពីនិន្នាការគួរអោយព្រួយបារម្ភណ៍ផងដែរ ដោយគ្រួសារកសិករមួយចំនួនបានផ្លាស់ប្តូរមករកការផលិតសំរាប់តែហូប។ ទិន្នន័យបង្ហាញថា ការធ្វើកសិកម្មសំរាប់តែហូបមានការកើនឡើង ១០% ហើយ ៥% នៃសំណាកបានផ្លាស់ប្តូរការផលិតសំរាប់ហូបនិងលក់ មកផលិតសំរាប់តែហូប។ ដំណាំស្រូវ បន្លែ[13] និងការរកអុស គឺជាប្រភេទផលិតកម្មដែលមានការប្រែប្រួលទៅរកការផលិតសំរាប់ហូប។ បើសិនជានិន្នាការនេះនៅតែបន្ត វានឹងបង្កផលប៉ះពាល់អវិជ្ជមានបន្ថែមទៀតដល់ចំណូលពីកសិកម្ម។

ចំពោះគ្រួសារដែលបន្តលក់កសិផលរបស់ពួកគេ យើងឃើញថា ចំណូល និងប្រាក់ចំណេញជាមធ្យមដែលបានពីសកម្មភាពកសិកម្មរបស់ពួកគេបានធ្លាក់ចុះគ្រប់ប្រភេទផលិតកម្មកសិកម្ម លើកលែងការចិញ្ចឹមសត្វ និងដំណាំស្រូវ។ ជាមធ្យម ចំណូលដុលពីកសិកម្មបានធ្លាក់ចុះ ៥៥% ចន្លោះខែមករា និងខែមេសា ចំណែកប្រាក់ចំណេញបានធ្លាក់ចុះ ៥៩% ក្នុងកំឡុងពេលដូចគ្នា។ បើទោះជាចំណាយផលិតកម្មបានធ្លាក់ចុះក្នុងកំឡុងពេលដូចគ្នាក៏ដោយ ការចំណេញពីផលិតកម្មដ៏នៅតែធ្លាក់ចុះខ្លាំងដោយសារការធ្លាក់ចុះតំលៃផលិតផលកសិកម្ម។ ប៉ុន្តែផលប៉ះពាល់នៃជំងឺកូវីដ-១៩ មានភាពខុសគ្នាទៅលើប្រភេទផលិតកម្មកសិកម្ម និងតាមខេត្ត/រាជធានី។ ផលចំណេញកសិកម្មនៅក្នុងខេត្តសៀមរាបបានធ្លាក់ចុះ ៥៣% ជាតួលេខខ្ពស់ជាងគេបើប្រៀបនឹងខេត្តផ្សេងៗ។ ដូចគ្នានេះដែរ តំលៃស្រូវក៏កើនឡើងគួរអោយកត់សំគាល់នឹងបានផ្តល់ផលវិជ្ជមានដល់កសិករមួយចំនួនផងដែរ។

[13] ការប្រែប្រួលរបស់ដំណាំបន្លែស្របទៅនឹងការរំពឹងទុកនៃការកើនឡើងថ្លៃបន្លែ ៦០% (WFP, 2020)